**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករទូរគមនាគមន៍កម្ពុជា**

លេខ:......០៥៨៨...... ន.ទ.ក.

# សេចក្តីសម្រេច

## ស្តីពី

## ការព្យួរអាជ្ញាបណ្ណប្រតិបត្តិការនិងផ្តល់សេវាអ៊ីនធឺណិតលេខ ០២០ ន.ទ.ក./ន.ន.ទ. ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០១៨ ដែលផ្តល់ជូនក្រុមហ៊ុន ប៊ី យូញៀន (ខេមបូឌា) ធេលីខម ឯ.ក

## និយ័តករទូរគមនាគមន៍កម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២០/១២៤៥ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងផ្តល់ឋានៈជាប្រធាន និងសមាជិកនៃនិយ័តករទូរគមនាគមន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់និយ័តករទូរគមនាគមន៍កម្ពុជា
- យោងអាជ្ញាបណ្ណប្រតិបត្តិការនិងផ្តល់សេវាអ៊ីនធឺណិតលេខ ០២០ ន.ទ.ក./ន.ន.ទ. ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០១៨ ដែលផ្តល់ជូនក្រុមហ៊ុន ប៊ី យូញៀន (ខេមបូឌា) ធេលីខម ឯ.ក
- យោងលិខិតលេខ ៣១២៨ បទ.អរ.នជ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងលិខិតលេខ ៨ បទ.អរ.នជ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២៦ របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងស្មារតីនៃកិច្ចប្រជុំពេញអង្គលើកទី១ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦ របស់និយ័តករទូរគមនាគមន៍កម្ពុជា

## សម្រេច

**ប្រការ ១.-**

ព្យួរអាជ្ញាបណ្ណប្រតិបត្តិការនិងផ្តល់សេវាអ៊ីនធឺណិតលេខ ០២០ ន.ទ.ក./ន.ន.ទ. ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០១៨ ដែលផ្តល់ជូន ក្រុមហ៊ុន ប៊ី យូញៀន (ខេមបូឌា) ធេលីខម ឯ.ក ចាប់ពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦។

**ប្រការ ២.-**

ក្រុមហ៊ុនប៊ី យូញៀន (ខេមបូឌា) ធេលីខម ឯ.ក ត្រូវអនុវត្តកាតព្វកិច្ចដូចខាងក្រោម៖

ក. ទូទាត់បំណុលស្វ័យប្រកាស (ចំណូលបែងចែក) និងបំណុលពាក់ព័ន្ធ ជូនក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (ក.ប.ទ.) ត្រឹមថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៦ និងត្រូវបំពេញកាតព្វកិច្ចចាំបាច់ទាំងអស់ តាមការណែនាំរបស់ ក.ប.ទ. និងនិយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក.)។

ខ. ផ្អាកការធ្វើប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន ជាអាទិ៍ ការទទួលចុះឈ្មោះឬផ្តល់សេវាអ៊ីនធឺណិតដល់អតិថិជនថ្មី និងការចុះកិច្ចសន្យាធុរកិច្ចជាមួយប្រតិបត្តិករទូរគមនាគមន៍ ឬក្រុមហ៊ុនជាដៃគូ។

គ. ទទួលខុសត្រូវចំពោះមុខច្បាប់និងបទប្បញ្ញត្តិជាធរមាននូវរាល់បញ្ហា ដែលអាចកើតមានឡើង ជាយថាហេតុបណ្ដាលមកពីការព្យួរអាជ្ញាបណ្ណនេះ។

**ប្រការ ៣.-**

អាជ្ញាបណ្ណនេះត្រូវព្យួរជាបណ្ដោះអាសន្នរហូតដល់ក្រុមហ៊ុនបំពេញកាតព្វកិច្ចបំណុលរួចរាល់ ត្រឹមថ្ងៃកំណត់ចុងក្រោយគឺថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៦។

ក្នុងករណីក្រុមហ៊ុនមិនអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងប្រការ ២ នៃសេចក្ដីសម្រេចនេះ ន.ទ.ក. នឹងអនុវត្តនីតិវិធីលុបអាជ្ញាបណ្ណប្រតិបត្តិការនិងផ្ដល់សេវាអ៊ីនធឺណិតលេខ ០២០ ន.ទ.ក./ន.ន.ទ. ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០១៨ ដែលផ្ដល់ជូនក្រុមហ៊ុន ប៊ី យូញៀន (ខេមបូឌា) ធេលីខម ឯ.ក ព្រមទាំងចាត់វិធានការផ្សេងទៀត ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

សមាជិក ន.ទ.ក. ប្រធាននាយកដ្ឋាននិងអង្គភាពក្រោមឱវាទ ន.ទ.ក. និងសាមីក្រុមហ៊ុន ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្ដីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៣កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦

**ប្រធាន**

**ថោង ចិន្តា**

**ចម្លងជូន:**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- ក្រសួងពាណិជ្ជកម្ម
- មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត
- គ្រប់ប្រតិបត្តិករទូរគមនាគមន៍
- គ្រប់ភ្នាក់ងារនាំចូល ផ្គត់ផ្គង់ និងចែកចាយ គ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ